អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងតំរៀបធុងសំរាមតាមពណ៌**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្ត្រ** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម៖

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ៖

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ៖

ទំហំនិងពណ៌៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ៖

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ៖

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្ត្រ** ៖ បំណិនសម្បទា៖ ចោលសំរាមក្នុងធុងសំរាម

**សិក្សាសង្គម** ៖ បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។

**បុរេគណិត** ៖ បំណិនសម្បទា៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។

បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសកាតធុងសំរាមដែលមានពីរប្រភេទ សខ្មៅ និងពណ៌។

កាតទាំងអស់ត្រូវកាត់ជាជួរតាមបន្ទាត់ឈរជាជួរ និងអ៊ុតវាឱ្យបានស្អាត សម្រាប់តែកាតពណ៌ទេ។ កាតសខ្មៅទុកសម្រាប់ផាត់ពណ៌ ដូច្នេះមិនចាំបាច់អ៊ុតទេ។ គម្របដបមួយចំនួនដែលមានមានគ្រប់ពណ៌ដូចនឹងកាត់ធុងសំរាម

(សម្រាប់ចែកទៅតាមក្រុមនីមួយៗ) ឬក្រដាសពណ៌ ឬជាអ្វីក៏បាន ឱ្យតែមានពណ៌ដូចទៅនឹងធុងសំរាមនីមួយៗជាការស្រេច។

**ការរៀបចំ** ៖ ត្រូវត្រៀម សម្ភារសម្រាប់លេងល្បែងនេះឱ្យបានគ្រប់គ្រាន់ ល្បែងនេះអាចលេងម្តងម្នាក់ ឬលេងជាក្រុមក៏បានដែរ វាអាស្រ័យលើកការសម្រេចចិត្តរបស់គ្រូ។

**សេចក្តីណែនាំ** ៖

1. មុននឹងលេងល្បែងនេះ ត្រូវសួរកុមារសំណួរមួយចំនួនសិន។
2. កូនៗស្គាល់ពណ៌ដែរឬទេ? ពណ៌អ្វីខ្លះ? ឱ្យកុមារប្រាប់ពណ៌នីមួយៗ។
3. ល្បែងនេះអាចលេងជាក្រុមក៏បាន ឬម្នាក់ៗក៏បានដែរ។ ប្រសិនបើលេងជាក្រុម អាចក្នុងមួយក្រុមមានកុមារ៤ទៅ៥នាក់ក្នុង១ក្រុម។
4. ប្រាប់កុមារពីរបៀបលេងល្បែងមួយនេះឱ្យបានច្បាស់ជាមុនសិន
    - ក្រុមនីមួយត្រូវមានសម្ភារឱ្យបានគ្រប់ទាំងអស់ ក្រដាសកាតធុងសំរាមដែលមាន៨សន្លឹក និងគម្របដប ឬក្រដាសពណ៌កាត់តូចៗ ដែលមានពណ៌ដូចនឹងធុងសំរាម និងចំនួនគ្រប់ទៅនឹងចំនួនធុងសំរាមដែរ។
    - លេងនៅលើតុក៏បាន លេងលើការ៉ូក៏បាន
    - សមាជិកនីមួយៗឈរ ឬអង្គុយជារង្វង់ និងតម្រៀបក្រដាសកាតធុងសំរាមជា៨កន្លែងដោយទុកចន្លោះសម្រាប់ដាក់គម្របដបដែលមានពណ៌ដូចជាធុងសំរាម និងដាក់គម្រងដបទាំងអស់នៅមួយកន្លែង។
    - ក្នុងក្រុមនីមួយៗអាចលេងបែបប្រកួតប្រជែងគ្នាបាន
    - ចាប់ផ្តើមលេងល្បែងនេះ ដោយតាមក្រុមនីមួយៗត្រូវដាក់តំរៀបគម្របដបពណ៌ទៅតាមពណ៌កាតធុងសំរាមដែលមានក្នុងក្រដាសកាតទាំងនោះ
    - ពួកគេត្រូវតំរៀបពណ៌ឱ្យត្រូវគ្នា ដូចគ្នា មិនឱ្យខុសពណ៌ទេ ដោយក្នុងសមាជិកក្នុងក្រុមនីមួយៗត្រូវជួយគ្នា សាមគ្គីគ្នា ដើម្បីប្រកួតប្រជែងជាមួយក្រុមផ្សេងៗទៀតផងដែរ។
    - ក្រុមណាដែលដាក់តំរៀបគម្របដបត្រូវពណ៌នឹងកាតធុងសំរាមរួចហើយ ត្រូវលើកដៃនឹងស្រែកថា ក្រុមខ្ញុំរួចរាល់ហើយ បន្ទាប់ពួកគេត្រូវឈប់ ហើយគ្រូត្រូវត្រួតពិនិត្រក្រុមនោះ ថាត្រឹមត្រូវដែរឬទេ។ បើខុសប្រាប់ឱ្យក្រុមនោះដាក់និងរៀបម្តងទៀតឱ្យបានត្រឹមត្រូវ។

- ក្រុមណាដែលរួចរាល់មុនគេ និងត្រឹមត្រូវ ក្រុមនោះនឹងក្លាយជាក្រុមដែលឈ្នះទី១ ទី២ ទី៣…

5. លេងបែបហ្នឹងនេះរហូត ដល់ពេលវេលាដែលបានកំណត់ ជាការស្រេច។

**ការប្រែប្រួល៖**

1. ល្បែងនេះអាចលេងម្នាក់ៗបាន
2. លេងដូចគ្នាទាំងអស់ ប៉ុន្តែគ្រាន់តែចែកក្រដាសកាតធុងសំរាមឱ្យម្នាក់សន្លឹកបានហើយ និងគម្របដបពណ៌ចំនួនទៅតាមចំនួនរបស់ធុងសំរាមក្នុងក្រដាសកាតនោះ។
3. អ្នកណាដែលដាក់បានមុន រួចមុន លើកដៃប្រាប់គ្រូ ថាខ្ញុំរួចរាល់ហើយ បន្ទាប់មក គ្រូត្រូវត្រួតពិនិត្រថាត្រឹមត្រូវអត់ដែរ។
4. ចំនែកឯក្រដាសដែលមានធុងសំរាមដែរ តែជាបប្រភេទសខ្មៅវិញ ពេលលេង កុមារម្នាក់ៗត្រូវដាក់គម្របដបពណ៌ជាជួរជាមុនសិន បន្ទាប់មកផាត់ពណ៌ធុងសំរាមទៅតាមពណ៌របស់គម្របដបដែលបានដាក់នេះជាការស្រេចតែម្តង។